ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ក្រុមការងារ

# សៀវភៅណែនាំ
# ស្តីពី
# ដំណើរការជ្រើសរើសគម្រោង
# អន្តរឃុំ សង្កាត់

354.968
COO

ខែកញ្ញា ឆ្នាំ២០០៧

# អារម្ភកថា

បទពិសោធន៍នៃការអនុវត្តគម្រោង និងកម្មវិធីមួយចំនួន ដែលបាន និងកំពុងគាំទ្រគម្រោងអន្តរឃុំ សង្កាត់ដូចជា កម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌ គម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ និងគម្រោង សហប្រតិបត្តិបត្តិការរវាងឃុំ សង្កាត់ និងឃុំ សង្កាត់ បានបង្ហាញឱ្យឃើញច្បាស់ថា គម្រោងអន្តរឃុំ សង្កាត់កំពុងបំពេញមុខនាទីយ៉ាងសំខាន់ ក្នុងការជួយគាំទ្រ និងសម្របសម្រួលដោះស្រាយជាមូលដ្ឋានមួយចំនួន ដែលឃុំ សង្កាត់ពុំមាន លទ្ធភាពក្នុងការសម្របសម្រួលដើម្បីដោះស្រាយ ។ លើសពីនេះទៅទៀត តាមរយៈការអនុវត្តនូវគម្រោង និងកម្មវិធីទាំងអស់នេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងសមត្ថភាព តួនាទី និងភារកិច្ចរបស់ថ្នាក់ស្រុក ខណ្ឌ និង បានបង្កើននូវកិច្ចសហការកាន់តែល្អប្រសើរបន្ថែមទៀតរវាងឃុំ សង្កាត់ និងឃុំ សង្កាត់ និងឃុំ សង្កាត់ជាមួយស្រុក ខណ្ឌ មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ។

កន្លងមក គម្រោង និងកម្មវិធីទាំងនេះ មានដំណើរការ និងនីតិវិធីសម្រាប់ជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់ ដាច់ដោយឡែកពីគ្នា ដែលមានការលំបាកក្នុងការអនុវត្ត និងសម្របសម្រួល ដោយថ្នាក់ឃុំ សង្កាត់ និងស្រុក ខណ្ឌ ។ ដូច្នេះទាមទារឱ្យមានការសម្របសម្រួលគ្នា រវាងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និងការចូលរួមពីមន្ត្រីមូលដ្ឋានពាក់ព័ន្ធក្នុងការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់ ។

ផ្អែកលើបទពិសោធន៍ និងចំណុចជាវិជ្ជមានខាងលើនេះ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ) បានឯកភាពឱ្យធ្វើការកែសម្រួលលើសេចក្តីណែនាំនានា ដែលបានអនុវត្តកន្លងមក និងរៀបចំជាសេចក្តីណែនាំរួមមួយស្តីពី **ដំណើរការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់** ដែលអាចប្រើប្រាស់បានដោយអ្នកពាក់ព័ន្ធទាំងអស់រួមមាន ស្ថាប័ន អង្គភាពរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ។

សេចក្តីណែនាំស្តីពី ដំណើរការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់នេះ នឹងធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកន្លងមក និងជាមូលដ្ឋានមួយដ៏សំខាន់ សម្រាប់អ្នកពាក់ព័ន្ធផ្សេងទៀត ដែលមានបំណងជួយគាំទ្រគម្រោងអន្តរឃុំ សង្កាត់ ពង្រឹងតួនាទី សមត្ថភាព និងរដ្ឋបាលនៅថ្នាក់ឃុំ សង្កាត់ និងស្រុក ខណ្ឌ ។

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានការសង្ឃឹមយ៉ាងមុតមាំថា ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង និងដៃគូអភិវឌ្ឍន៍ទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមសេចក្តីណែនាំនេះ ប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យ ។

ភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៧

**ប្រធានក្រុមការងាររបស់ គ.ជ.វ.វ**

ប្រ៊ុំ សុខា

# មាតិកា


| ផ្នែក | ចំណងជើង | ទំព័រ |
|---|---|---|
| | អារម្ភកថា | i |
| | មាតិកា | ii |
| ១. | សេចក្តីផ្តើម | ១ |
| ២. | គោលបំណង | ១ |
| ៣. | កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំ | ២ |
| ៤. | ដំណើរការកំណត់ និងជ្រើសរើសគម្រោង | ៦ |
| | ៤.១. ការកំណត់គម្រោងអន្តរឃុំ សង្កាត់ | ៧ |
| | ៤.២. បូកសរុប និងចាត់អាទិភាពគម្រោង | ១៣ |
| | ៤.៣. ការបង្ហាញគម្រោងក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ | ១៩ |
| | ៤.៤. ការជ្រើសរើសគម្រោងដើម្បីប្រើប្រាស់មូលនិធិ និងកំណត់ភ្នាក់ងារអនុវត្ត | ២១ |
| | ឧបសម្ព័ន្ធទី ១ : តារាងបញ្ជីវិស័យ ប្រភេទគម្រោង និងមន្ទីរទទួលបន្ទុក | ២៨ |
| | ឧបសម្ព័ន្ធទី ២ : | ៣០ |
| | ទម្រង់ទី១.១ក គម្រោងអន្តរឃុំ សង្កាត់ ដែលកំណត់ដោយឃុំ សង្កាត់ | ៣០ |
| | ទម្រង់ទី១.១ខ គម្រោងអន្តរឃុំ សង្កាត់ ដែលកំណត់ដោយស្រុក ខណ្ឌ | ៣១ |
| | ទម្រង់ទី១.២ បញ្ជីគម្រោងអន្តរឃុំ សង្កាត់អាទិភាព | ៣២ |
| | ទម្រង់ទី១.៣ ការពិនិត្យជ្រើសរើសគម្រោង តាមរយៈលក្ខណៈវិនិច្ឆ័យ | ៣៣ |
| | ទម្រង់ទី២.១ បញ្ជីគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តអន្តរឃុំ សង្កាត់ជាអាទិភាព | ៣៤ |
| | ទម្រង់ទី២.២ បញ្ជីគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្តអន្តរឃុំ សង្កាត់ជាអាទិភាព | ៣៥ |
| | ទម្រង់ទី៣.១ ការដាក់ពិន្ទុគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | ៣៦ |
| | ទម្រង់ទី៣.២ ការដាក់ពិន្ទុគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត | ៣៧ |
| | ទម្រង់ទី៣.៣ ការចាត់អាទិភាពគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | ៣៨ |
| | ទម្រង់ទី៣.៤ ការចាត់អាទិភាពគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត | ៣៩ |
| | ទម្រង់ទី៤.១ ការបូកសរុបពិន្ទុគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាអាទិភាព | ៤០ |

**ផ្នែក ចំណងជើង** **ទំព័រ**


| | | |
|---|---|---|
| **ឧម្រង់ទី៤.២** | ការបូកសរុបពិន្ទុគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្តជាអាទិភាព | ៤១ |
| **ឧម្រង់ទី៤.៣** | ការបូកសរុបសំលេងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាអាទិភាព | ៤២ |
| **ឧម្រង់ទី៤.៤** | ការបូកសរុបសំលេងគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្តជាអាទិភាព | ៤៣ |
| **ឧម្រង់ទី៥.១** | បញ្ជីគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាអាទិភាព | ៤៤ |
| **ឧម្រង់ទី៥.២** | បញ្ជីគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្តជាអាទិភាព | ៤៥ |
| **ឧម្រង់ទី៦.១** | សំណើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តអាទិភាព | ៤៦ |
| **ឧម្រង់ទ៦.២** | សំណើគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្តអាទិភាព | ៤៧ |
| **ឧម្រង់ទី៧.១** | សំណើភ្នាក់ងារអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តអាទិភាព | ៤៨ |
| **ឧម្រង់ទី៧.២** | សំណើភ្នាក់ងារអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្តអាទិភាព | ៤៩ |

# ដំណើរការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់

## ១. សេចក្តីផ្តើម

នៅពេលដែលការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ត្រូវបាន និងកំពុងដំណើរការប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាពក្រោមការគ្រប់គ្រង និងសម្របសម្រួលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ចំណុចដែលត្រូវយកចិត្តទុកដាក់ថ្មីមួយទៀតគឺ គម្រោងអន្តរឃុំ សង្កាត់ ។ តាមរយៈបទពិសោធន៍ថ្មីៗនៃការអនុវត្តកម្មវិធីពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌដែលគាំទ្រដោយគម្រោងគាំទ្រការអភិវឌ្ឍបែបប្រជាធិបតេយ្យ ក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) គម្រោងគ្រប់គ្រងធនធានធម្មជាតិ និងលើកកំពស់ជីវភាពរស់នៅ (NRML) និងគម្រោងសហប្រតិបត្តិការរវាងឃុំ សង្កាត់ និងឃុំ សង្កាត់ ដែលគាំទ្រដោយសហគមន៍អ៊ឺរ៉ុប និងកម្មវិធី អភិវឌ្ឍរបស់អង្គការសហប្រជាជាតិ (EC-UNDP) បានបង្ហាញឱ្យឃើញថា គម្រោងអន្តរឃុំ សង្កាត់មានលក្ខណៈ សមស្របក្នុងការជួយបំពេញ និងឆ្លើយតបតម្រូវការអន្តរឃុំ សង្កាត់ ក៏ដូចជាជួយបំពេញការខ្វះលទ្ធភាពរបស់ឃុំ សង្កាត់ក្នុងការគាំទ្រគម្រោង ដែលមានទីតាំងស្ថិតនៅក្រៅឃុំ សង្កាត់របស់ខ្លួន ។ ម្យ៉ាងទៀត បទពិសោធន៍នៃគម្រោងខាងលើក៏បានជួយពង្រឹងកិច្ចសហការរវាងឃុំ សង្កាត់ និងឃុំ សង្កាត់ និងរវាងឃុំ សង្កាត់ជាមួយថ្នាក់ស្រុក ខណ្ឌក្នុងការងារអភិវឌ្ឍន៍ក៏ដូចជាការងាររដ្ឋបាល និងអភិបាលកិច្ចមូលដ្ឋាន ។

លើសពីនេះទៀត ការអនុវត្តគម្រោងអន្តរឃុំ សង្កាត់បានរួមចំណែកយ៉ាងសំខាន់ ក្នុងការពង្រឹងតួនាទី ចំណេះដឹង និងសមត្ថភាពរបស់ថ្នាក់ស្រុក ខណ្ឌ ស្ថាប័ន និងអង្គភាពនានា ដែលពាក់ព័ន្ធនឹងការជួយគាំទ្រ និងដោះស្រាយបញ្ហានានា ដែលលើសពីលទ្ធភាព និងសមត្ថកិច្ចរបស់ឃុំ សង្កាត់ ហើយដែលចំណុចនេះមិនទាន់បានយកចិត្តទុកដាក់គ្រប់គ្រាន់នៅឡើយ ដោយអ្នកពាក់ព័ន្ធ ។ ចំណុចសំខាន់ដូចគ្នានេះដែរគឺ ការពង្រឹងតួនាទី និងសមត្ថភាពស្រុក ខណ្ឌមានលក្ខណៈសមស្របទៅនឹងក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់គ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ដែលកំពុងរៀបចំដោយក្រសួងមហាផ្ទៃ ។

ផ្អែកលើចំណុចសំខាន់ខាងលើ តម្រូវឱ្យមានការរៀបចំជាដំណើរការសមស្របមួយសម្រាប់គាំទ្រ និងដោះស្រាយបញ្ហាដែលពាក់ព័ន្ធពីឃុំ សង្កាត់មួយទៅឃុំ សង្កាត់មួយទៀត " អន្តរឃុំ សង្កាត់ " តាមរយៈស្ថាប័ន អង្គភាព ឬរចនាសម្ព័ន្ធមួយដែលមានលក្ខណៈសមស្រប ជាមួយនឹងការគាំទ្រផ្នែកបច្ចេកទេស និងថវិកា ដែលអាចដោះស្រាយបញ្ហាអន្តរឃុំ សង្កាត់នេះ ហើយអាចប្រើប្រាស់បាន ដោយដៃគូអភិវឌ្ឍន៍នានា ដែលមានបំណងក្នុងការជួយគាំទ្រគម្រោងអន្តរឃុំ សង្កាត់ ។

## ២. គោលបំណង

ដំណើរការនៃការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់មិនមែនជាដំណើរការថ្មីមួយនៃការកសាងផែនការអន្តរឃុំ សង្កាត់ឡើយ តែវាជាដំណើរការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់ ផ្អែកជាមូលដ្ឋានលើបញ្ហា តម្រូវការ

និងដំណោះស្រាយ ដែលបានកំណត់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ តាមរយៈដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។ ជាមួយគ្នានេះដែរ គម្រោងអន្តរឃុំ សង្កាត់ក៏ត្រូវរៀបចំឱ្យស្របគ្នាជាមួយនឹងគោលដៅអភិវឌ្ឍន៍នៃផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ខេត្ត ក្រុង និងគោលនយោបាយ របស់រាជរដ្ឋាភិបាលផងដែរ ។

គោលបំណងសំខាន់ៗនៃដំណើរការនៃការជ្រើសរើសគម្រោងនេះ គឺ :

- កំណត់គម្រោងដែលមានលក្ខណៈអន្តរឃុំ សង្កាត់នៅក្នុងស្រុក ខណ្ឌ
- ពង្រឹងសមត្ថភាពស្ថាប័ន អង្គភាព និងរចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងសម្របសម្រួលគម្រោង និងដោះស្រាយបញ្ហាអន្តរឃុំ សង្កាត់
- ពង្រឹងការសហការរវាងឃុំ សង្កាត់ និងឃុំ សង្កាត់ ក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន
- រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការអនុវត្តគម្រោងអន្តរឃុំ សង្កាត់ ។

ដើម្បីធានាឱ្យគម្រោងអន្តរឃុំ សង្កាត់ឆ្លើយតបនឹងតម្រូវការរបស់មូលដ្ឋាន ដំណើរការនៃការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់ ត្រូវអនុវត្តទៅតាមនីតិវិធី ដែលមានរៀបរាប់ដូចខាងក្រោម :

## ៣. កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំ

កិច្ចប្រជុំផ្សព្វផ្សាយអំពីសេចក្តីណែនាំ ជាសកម្មភាពមួយដ៏សំខាន់ ដែលត្រូវអនុវត្តឱ្យបានសមស្រប និងច្បាស់លាស់ ដើម្បីធានាថា គ្រប់មន្ត្រីពាក់ព័ន្ធនៅថ្នាក់ឃុំ សង្កាត់ ស្រុក ខណ្ឌ និងខេត្ត ក្រុងយល់ច្បាស់អំពី សេចក្តីណែនាំនេះ ។

គោលបំណងសំខាន់នៃកិច្ចប្រជុំនេះគឺ ធ្វើការផ្សព្វផ្សាយសេចក្តីណែនាំអំពីដំណើរការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់ដល់មន្ត្រីថ្នាក់ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអង្គភាពស្ថាប័ន ដែលមានការពាក់ព័ន្ធដទៃទៀត ដើម្បីឱ្យមានការយល់ច្បាស់អំពីដំណើរការ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគម្រោង តួនាទី និងភារកិច្ចរបស់ថ្នាក់ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលពាក់ព័ន្ធក្នុងការកំណត់ និងជ្រើសរើសគម្រោងនេះ ។ អភិបាលស្រុក ខណ្ឌជាអ្នកដើរតួសំខាន់ក្នុងដឹកនាំការរៀបចំ និងសម្របសម្រួលកិច្ចប្រជុំនេះ ដោយមានការសហការ និងគាំទ្រពីមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ។ ក្នុងការរៀបចំកិច្ចប្រជុំនេះ អភិបាលស្រុក ខណ្ឌអាចចាត់អភិបាលរង ឬមន្ត្រីជំនាញថ្នាក់ស្រុក ខណ្ឌឱ្យបង្ហាញពីសេចក្តីណែនាំ និងឯកសារផ្សេងៗដែលពាក់ព័ន្ធ ចំណែកឯកមន្ត្រីសម្របសម្រួលថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីគាំទ្របច្ចេកទេស ដែលប្រចាំការនៅក្នុងស្រុក ខណ្ឌនោះ ជាអ្នកសហការ និងគាំទ្រក្នុងការរៀបចំកិច្ចប្រជុំដូចជា ជួយពន្យល់អំពីលក្ខណៈបច្ចេកទេសនៃសេចក្តីណែនាំ និងសម្របសម្រួលលើការរៀបចំឯកសារ

និងសម្ភារៈសម្រាប់កិច្ចប្រជុំជាដើម ។ ភារកិច្ចជាក់លាក់ជាក់លាក់របស់អ្នកពាក់ព័ន្ធ ក្នុងការរៀបចំកិច្ចប្រជុំនេះ មានរៀបរាប់ដូចខាងក្រោម :

| **អ្នកទទួលខុសត្រូវ** | **ភារកិច្ច** |
|---|---|
| អភិបាលស្រុក ខណ្ឌ | • ចាត់ចែង រៀបចំ និងសម្របសម្រួលកិច្ចប្រជុំ ដូចជា ការអញ្ជើញអ្នកពាក់ព័ន្ធចូលរួម ទីកន្លែងជាដើម |
| មន្ត្រីជំនាញស្រុក ខណ្ឌ ( ចាត់តាំងដោយអភិបាលស្រុក ខណ្ឌ) | • បង្ហាញពីសេចក្តីណែនាំ និងដំណើរការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់<br>• រៀបចំការបង្ហាញ និងឯកសារដែលពាក់ព័ន្ធ |
| មន្ត្រីសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងស្រុក ខណ្ឌ | • ជួយគាំទ្រមន្ត្រីជំនាញថ្នាក់ស្រុក ខណ្ឌក្នុងការក្នុងការបង្ហាញពីសេចក្តីណែនាំ<br>• ជួយមន្ត្រីថ្នាក់ស្រុក ខណ្ឌក្នុងការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ |
| មន្ត្រីគាំទ្របច្ចេកទេស | • ជួយមន្ត្រីថ្នាក់ស្រុក ខណ្ឌរៀបចំកិច្ចប្រជុំ និងពន្យល់ពីលក្ខណៈបច្ចេកទេសនៃគម្រោង |

កិច្ចប្រជុំនេះត្រូវរៀបចំនៅថ្នាក់ស្រុក ខណ្ឌ ដោយមានសមាសភាពចូលរួមៈ អភិបាល អភិបាលរងស្រុក ខណ្ឌ មន្ត្រី ការិយាល័យចំណុះសាលាស្រុក ខណ្ឌ មន្ត្រីការិយាល័យជំនាញ មន្ត្រីសម្របសម្រួលស្រុក ខណ្ឌ និងខេត្ត ក្រុង មន្ត្រីគាំទ្របច្ចេកទេស ដែលបំពេញការងារនៅក្នុងស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងជំនួយការគម្រោងគ្រប់គ្រងធនធានធម្មជាតិឃុំ សង្កាត់ ។

កិច្ចប្រជុំ ក៏ត្រូវពិភាក្សាផងដែរអំពីកម្មវិធី ដែលត្រូវអនុវត្តនៅជំហានបន្ទាប់នៅថ្នាក់ឃុំ សង្កាត់ និងស្រុក ខណ្ឌ ដើម្បីកំណត់ និងបូកសរុបគម្រោង ឬសកម្មភាពអន្តរឃុំ សង្កាត់ ដែលកំណត់ដោយឃុំ សង្កាត់ និងស្រុក ខណ្ឌ ។

ការកំណត់គម្រោងអន្តរឃុំ សង្កាត់ ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវពិចារណាលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម :

(១). ជាគម្រោង ឬសកម្មភាព ដែលលើកឡើងដោយឃុំ សង្កាត់ និងស្រុក ខណ្ឌដូចជា គម្រោង ឬសកម្មភាពដែលមាននៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ និងគម្រោង ឬសកម្មភាពផ្សេងទៀតដែល ឆ្លុះបញ្ចាំងនៅក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំ សង្កាត់ និងស្រុក ខណ្ឌ

(២). ជាគម្រោង ឬសកម្មភាពដែលផ្តល់ផលប្រយោជន៍ចាប់ពីពីរឃុំ សង្កាត់ឡើងទៅ

(៣). ជាគម្រោង ឬសកម្មភាពអាទិភាព ដែលមានលក្ខណៈសមស្របទៅនឹងសេចក្តីណែនាំផ្នែកបច្ចេកទេស (ត្រូវមានការអនុម័តផ្នែកបច្ចេកទេសដោយមន្ទីរជំនាញ មានការសិក្សាផលប៉ះពាល់បរិស្ថាន ការសិក្សាដីធ្លី និងការសិក្សាផលប៉ះពាល់លើស្ត្រី និងកុមារ ... ។ល ។)

(៤). បើជាគម្រោង ឬសកម្មភាពផ្តល់សេវាកម្មសង្គម ត្រូវតែអនុវត្តនៅក្នុងតំបន់ដែលមានតម្រូវការសេវានោះខ្លាំងជាងគេ (ក្នុងភូមិ ឃុំ សង្កាត់ដែលក្រីក្រជាងគេ ឬក៏ជាភូមិ ឃុំ សង្កាត់ ដែលមានបញ្ហាសង្គមខ្លាំងជាងគេដូចជា គម្រោងគាំទ្រថ្នាក់អក្ខរកម្ម អប់រំពីសុខភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការពារ និងទប់ស្កាត់ ជម្ងឺអេដស៍ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារជាដើម) ។

(៥). បើជាគម្រោង ឬសកម្មភាពអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច គួរមានការសិក្សាផ្នែកសេដ្ឋកិច្ច ដើម្បីបង្ហាញ ថាគម្រោងនោះមានផលចំណេញផ្នែកសេដ្ឋកិច្ច ច្រើនជាងតម្លៃគម្រោង ។

(៦). ជាគម្រោង ឬសកម្មភាពវិនិយោគដែលផ្តល់ផលប្រយោជន៍ភាគច្រើនដល់ស្ត្រី និងកុមារ ។

(៧). ជាគម្រោង ឬសកម្មភាពវិនិយោគ ដែលពុំមានផលប៉ះពាល់អវិជ្ជមានដល់ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ។

**តារាងសង្ខេបសកម្មភាពប្រជុំផ្សព្វផ្សាយសេចក្តីណែនាំ**

| សកម្មភាព | លទ្ធផល | សម្ភារចាំបាច់ | រយៈពេល | អ្នកចូលរួម | អ្នកសំរបសំរួល | អ្នកសង្កេតការណ៍ |
|---|---|---|---|---|---|---|
| ១). ប្រជុំផ្សព្វផ្សាយនៅថ្នាក់ស្រុក ខណ្ឌអំពីដំណើរការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់<br>២). រៀបចំកម្មវិធីប្រជុំដើម្បីកំណត់ និងបូកសរុបគម្រោងអន្តរឃុំ សង្កាត់នៅថ្នាក់ឃុំ សង្កាត់ និងស្រុក ខណ្ឌ ។ | • ស្រុក ខណ្ឌ និងឃុំ សង្កាត់យល់ច្បាស់ អំពីដំណើរការ ជ្រើសរើសគម្រោង អន្តរឃុំ សង្កាត់<br>• កម្មវិធីប្រជុំកំណត់ និងជ្រើសរើស គម្រោងអន្តរឃុំ សង្កាត់នៅថ្នាក់ឃុំ សង្កាត់ និងស្រុក ខណ្ឌ | • សៀវភៅ សេចក្តីណែនាំ អំពីដំណើរការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់ និងឯកសារពាក់ព័ន្ធ | ១ថ្ងៃ | • មន្ត្រីចំណុះសាលាស្រុក ខណ្ឌ<br>• មន្ត្រីជំនាញថ្នាក់ស្រុក ខណ្ឌ<br>• មន្ត្រីសម្របសម្រួល ស្រុក ខណ្ឌ ខេត្ត ក្រុង និងមន្ត្រីគាំទ្របច្ចេកទេសប្រចាំការនៅក្នុងស្រុក ខណ្ឌ<br>• មេឃុំ ចៅសង្កាត់<br>• ស្មៀន<br>• អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់<br>• ជនបង្គោល NREM (ឃុំ សង្កាត់បើមាន) | • អភិបាលស្រុក ខណ្ឌ និងមន្ត្រីជំនាញថ្នាក់ស្រុក ខណ្ឌ | • មន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង<br>• ... |

## ៤. ដំណើរការកំណត់ និងជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់

**និយមន័យទូទៅ :**

**ជាគម្រោង ដែលផ្តល់ផលប្រយោជន៍ច្រើនឃុំ សង្កាត់** ។ គម្រោងទាំងនេះជាគម្រោង ដែលមានទីតាំងចាប់ពីពីរឃុំសង្កាត់ឡើងទៅ ឬជាគម្រោងមានទីតាំងនៅក្នុងឃុំ សង្កាត់តែមួយ ឬមានទីតាំងអនុវត្តនៅកន្លែងណាមួយផ្សេងទៀត ។ គម្រោងអន្តរឃុំ សង្កាត់អាចជា**គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** និងជា**គម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត** (physical infrastructure and non-physical infrastructure projects) ។ ឧទាហរណ៍ជាក់ស្តែង គម្រោងអន្តរឃុំ សង្កាត់ អាចជាគម្រោងទាំងឡាយណា ដែលមានលក្ខណៈ សំគាល់ដូចខាងក្រោម :

- ជាគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានទីតាំងជាប់គ្នាស្ថិតនៅច្រើនឃុំ សង្កាត់ ឬ
- ជាគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានទីតាំងស្ថិតនៅក្នុងឃុំ សង្កាត់តែមួយ តែផ្តល់ផលប្រយោជន៍ ដល់ឃុំ សង្កាត់ជាច្រើនដូចជា គម្រោងសាលារៀន មណ្ឌលសុខភាព និងប្រព័ន្ធធារាសាស្ត្រ ជាដើម...ឬ
- ជាគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពាក់កណ្តាលសាធារណៈ ដែលជាតម្រូវការចាំបាច់ និងអាទិភាព របស់ឃុំ សង្កាត់ជាច្រើនដូចជា គម្រោងអណ្តូងទឹកស្អាត និងស្រះភូមិ ជាដើម... ឬ
- ជាគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត ដែលជាតម្រូវការចាំបាច់ និងអាទិភាពរបស់ឃុំ សង្កាត់ជាច្រើនដូចជា គម្រោងផ្សព្វផ្សាយ និងបង្ហាញពីការចិញ្ចឹមសត្វ ដំណាំស្រូវ វគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាល និងយុទ្ធនាការចាក់វ៉ាក់សាំងជាដើម និង
- ជាគម្រោងផ្សេងទៀត ដែលបង្ហាញពីផលប្រយោជន៍អន្តរឃុំ សង្កាត់ ។

ពិនិត្យលើលក្ខណៈជាក់ស្តែងរបស់គម្រោងអន្តរឃុំ សង្កាត់ដូចបានរៀបរាប់ខាងលើដូចជាទំហំ និងលក្ខណៈបច្ចេកទេស ការកំណត់ និងការជ្រើសរើសគម្រោងនេះត្រូវមានការទទួលខុសត្រូវដោយឃុំ សង្កាត់ជាច្រើនសហការគ្នា និងក្រោមការចូលរួម សម្របសម្រួលដោយថ្នាក់ស្រុក ខណ្ឌ ដែលមានតួនាទីសមស្របក្នុងការជួយគាំទ្រដល់ឃុំ សង្កាត់ ទាំងកិច្ចការរដ្ឋបាល និងការងារអភិវឌ្ឍន៍ ។ ដូច្នេះ ដំណើរការកំណត់ និងជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់ត្រូវអនុវត្តរួមគ្នា ដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងស្រុក ខណ្ឌ ដែលរួមមានអាជ្ញាធរ និងការិយាល័យជំនាញជុំវិញស្រុក ខណ្ឌ ។

ដំណើរការកំណត់ និងជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់នេះត្រូវអនុវត្តទៅតាមសកម្មភាពនីមួយៗ ដែលមានរៀបរាប់ដូចខាងក្រោម :

## ៤.១. ការកំណត់គម្រោងអន្តរឃុំ សង្កាត់

ការកំណត់ និងជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់អនុវត្តដោយថ្នាក់ស្រុក ខណ្ឌ និងឃុំ សង្កាត់ ហើយចែកចេញជាពីរដំណាក់កាលគឺ :

១. ការកំណត់គម្រោងដោយឃុំ សង្កាត់នៅថ្នាក់ឃុំ សង្កាត់

២. ការកំណត់គម្រោងដោយថ្នាក់ស្រុក ខណ្ឌ នៅថ្នាក់ស្រុក ខណ្ឌ

### ក). ការកំណត់គម្រោងដោយឃុំ សង្កាត់នៅថ្នាក់ឃុំ សង្កាត់ :

ការងារនេះរៀបចំនៅថ្នាក់ឃុំ សង្កាត់នៅក្នុងជំហានទី១នៃដំណើរការរៀបចំកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ឃុំ សង្កាត់ គឺបន្ទាប់ពីឃុំ សង្កាត់បានបូកសរុបបញ្ហា តម្រូវការ និងដំណោះស្រាយ ដែលបានកំណត់នៅថ្នាក់ឃុំ សង្កាត់ និងភូមិរួចមក ។ គោលបំណងសំខាន់នៃកិច្ចប្រជុំនេះ គឺការកំណត់គម្រោងអន្តរឃុំ សង្កាត់ ។ សមាសភាពចូលរួមអង្គប្រជុំនេះ រួមមាន គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ (គ.ផ.ថ) អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និង ជំនួយការគម្រោងគ្រប់គ្រងធនធានធម្មជាតិឃុំ សង្កាត់ ។ មេឃុំ ចៅសង្កាត់ ជាអ្នកសម្របសម្រួលកិច្ចប្រជុំនេះ ដោយមានការជួយគាំទ្រពីមន្ត្រីសម្របសម្រួលស្រុក ខណ្ឌ ។ ភារកិច្ចជាក់លាក់របស់អ្នកពាក់ព័ន្ធក្នុងការរៀបចំកិច្ចប្រជុំនេះ មានរៀបរាប់ដូចខាងក្រោម :

| អ្នកទទួលខុសត្រូវ | ភារកិច្ច |
|---|---|
| មេឃុំ ចៅសង្កាត់ | • ដឹកនាំរួមការរៀបចំ និងសម្របសម្រួលកិច្ចប្រជុំ |
| គ.ផ.ថ ឃុំ សង្កាត់ | • ចូលរួមពិភាក្សា និងកំណត់គម្រោងអន្តរឃុំ សង្កាត់ |
| មន្ត្រីសម្របសម្រួលថ្នាក់ស្រុក ខណ្ឌ និងខេត្ត ក្រុង | • ជួយគាំទ្រគ.ផ.ថ ក្នុងដំណើរការកំណត់គម្រោងអន្តរឃុំ សង្កាត់ និងរៀបចំឯកសារដែលពាក់ព័ន្ធ |
| ជំនួយការគម្រោងគ្រប់គ្រងធនធានធម្មជាតិឃុំ សង្កាត់ | • ចូលរួម និងជួយគ.ថ.ថ ក្នុងការកំណត់គម្រោងពាក់ព័ន្ធនឹងបញ្ហាធនធាន ធម្មជាតិ និងជីវភាពរស់នៅ និងការប្រើប្រាស់ឧបករណ៍ផ្សេងៗ ដែលពាក់ព័ន្ធនឹងបញ្ហានេះ |
| អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ | • ចូលរួម និងជួយគ.ផ.ថ ក្នុងកំណត់គម្រោងពាក់ព័ន្ធនឹងបញ្ហាស្ត្រី និងកុមារ |
| ស្មៀនឃុំ សង្កាត់ | • ជួយមេឃុំ ចៅសង្កាត់ ក្នុងការរៀបចំកិច្ចប្រជុំដូចជា សម្ភារៈ និងឯកសារផ្សេងៗដែលពាក់ព័ន្ធ<br>• កត់ត្រា និងធ្វើរបាយការណ៍ស្តីពីគម្រោងអន្តរឃុំ សង្កាត់ដែលបានកំណត់ដោយឃុំ សង្កាត់ |

| | | |
|---|---|---|
| | | • រៀបចំ និងផ្ញើទម្រង់ ១.១ក មកស្រុក ខណ្ឌ |

សកម្មភាពសំខាន់ៗ នៃកិច្ចប្រជុំនេះរួមមាន :

(១). កំណត់គម្រោងអន្តរឃុំ សង្កាត់ តាមរយៈការវិភាគដោយផ្អែកលើ :

- តារាងបញ្ហា តម្រូវការ និងដំណោះស្រាយ ដែលបានរៀបចំដោយឃុំ សង្កាត់នៅក្នុងជំហានទី១ នៃកម្មវិធីវិនិយោគឃុំ សង្កាត់ (តារាង ១.១) ។ **ក្នុងតារាងនេះ ក្ខឡោនដំណោះស្រាយជាមូលដ្ឋានសំខាន់សម្រាប់ការពិនិត្យពិចារណា ដើម្បីកំណត់គម្រោងអន្តរឃុំ សង្កាត់ ។**
- ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- ផែនទីឃុំ សង្កាត់ និងស្រុក ខណ្ឌ
- ផែនទីបញ្ហា មូលហេតុ ដំណោះស្រាយ និងផែនទីសកម្មភាពនៃការគ្រប់គ្រងធនធានធម្មជាតិ (បើមាន ជាពិសេសនៅក្នុងខេត្ត ក្រុង ដែលគាំទ្រដោយគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ NRML) និងផែនទីផ្សេងទៀត
- បទពិសោធន៍ ។

(២). ស្រង់គម្រោងអន្តរឃុំ សង្កាត់ ដែលបានកំណត់ចូលក្នុងទម្រង់ទី ១.១ក (សេចក្តីណែនាំជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់) និងបំពេញព័ត៌មានផ្សេងទៀត នៅក្នុងទម្រង់នេះដូចជា ប្រភេទគម្រោង ទីតាំង និងឃុំ សង្កាត់ពាក់ព័ន្ធជាដើម ។ ការរៀបរាប់អំពី វិស័យ ប្រភេទគម្រោងពាក់ព័ន្ធ និងមន្ទីរទទួលបន្ទុកមាននៅក្នុងឧបសម្ព័ន្ធទី ១ ។

(៣). ផ្ញើគម្រោងអន្តរឃុំ សង្កាត់ (ទម្រង់ទី ១.១ក) មកស្រុក ខណ្ឌ ដើម្បីធ្វើការបូកសរុប និងត្រៀមសំរាប់ការរៀបចំប្រជុំបូកសរុបរួមនៅថ្នាក់ស្រុក ខណ្ឌ ។

## តារាងសង្ខេបសកម្មភាពប្រជុំកំណត់គម្រោងនៅថ្នាក់ឃុំ សង្កាត់

| សកម្មភាព | លទ្ធផល | សម្ភារចាំបាច់ | រយៈពេល | អ្នកចូលរួម | អ្នកសំរបសំរួល | អ្នកសង្កេតការណ៍ |
|---|---|---|---|---|---|---|
| ១). កំណត់តំរូវការគម្រោងអន្តរឃុំ សង្កាត់ នៅថ្នាក់ឃុំ សង្កាត់តាមរយៈបញ្ហា តម្រូវការ និងដំណោះស្រាយស្នើឡើង នៅជំហានទី១ (តារាងទី១.១) នៃកម្មវិធីវិនិយោគឃុំ សង្កាត់ វិភាគផែនទី និងបទពិសោធន៍<br>២). ស្រង់គម្រោងអន្តរឃុំ-សង្កាត់ ចូលក្នុងទម្រង់ទី១.១ក និងបំពេញព័ត៌មានផ្សេងទៀតក្នុងទម្រង់នេះ<br>៣). ផ្ញើគម្រោងអន្តរឃុំ សង្កាត់ ទម្រង់ទី ១.១ក មកស្រុក ខណ្ឌ ដើម្បីធ្វើការបូកសរុប និងត្រៀមសំរាប់ការរៀបចំប្រជុំបូកសរុបរួមនៅថ្នាក់ស្រុក ខណ្ឌ ។ | • បញ្ជីគម្រោងអន្តរឃុំ សង្កាត់ កំណត់ដោយឃុំ សង្កាត់ | • ទម្រង់ទី១.១ក<br>• ផែនទីឃុំ សង្កាត់<br>• ផែនទីបញ្ហា មូលហេតុ ដំណោះស្រាយ និងផែនទីសកម្មភាព<br>• តារាងទី ១.១ នៃជំហានទី១របស់កម្មវិធីវិនិយោគឃុំ សង្កាត់ | ១ថ្ងៃ | • គណៈកម្មការកសាងផែនការ និងថវិកាឃុំ សង្កាត់ (គ.ផ.ថ)<br>• អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ<br>• ជំនួយការគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | • មេឃុំ ចៅសង្កាត់ និងជាប្រធានគ.ផ.ថ | • មន្ត្រីសម្របសម្រួល និងមន្ត្រីថ្នាក់ស្រុក ខណ្ឌ |

## ខ). ការកំណត់គម្រោងដោយថ្នាក់ស្រុក ខណ្ឌ នៅថ្នាក់ស្រុក ខណ្ឌ :

ការងារនេះរៀបចំនៅថ្នាក់ស្រុក ខណ្ឌ និងមានគោលបំណងក្នុងការកំណត់គម្រោងអន្តរឃុំ សង្កាត់ ដោយមន្ត្រីថ្នាក់ស្រុក ខណ្ឌ ។ សមាសភាពចូលរួមអង្គប្រជុំនេះរួមមាន អភិបាល អភិបាលរងស្រុក ខណ្ឌ មន្ត្រីការិយាល័យចំណុះសាលាស្រុក ខណ្ឌ មន្ត្រីការិយាល័យជំនាញជុំវិញស្រុក ខណ្ឌ និងតំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ។

អភិបាលស្រុក ខណ្ឌជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងដឹកនាំរួមនៃកិច្ចប្រជុំនេះ ដោយមានការសហការ និងគាំទ្រពីមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ។ ក្នុងកិច្ចដំណើរការកិច្ចប្រជុំ អភិបាលស្រុក ខណ្ឌត្រូវចាត់តាំងអភិបាលរង ឬមន្ត្រីជំនាញថ្នាក់ស្រុក ខណ្ឌណាម្នាក់ដើម្បីសម្របសម្រួល ចំណែកឯមន្ត្រីសម្របសម្រួលថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីគាំទ្របច្ចេកទេស ដែលប្រចាំការនៅក្នុងស្រុក ខណ្ឌនោះជាអ្នកសហការ និងគាំទ្រក្នុងការរៀបចំកិច្ចប្រជុំដូចជា ការជួយពន្យល់អំពីនីតិវិធីកំណត់គម្រោង និងសម្របសម្រួលលើការរៀបចំឯកសារ និងសម្ភារៈសម្រាប់កិច្ចប្រជុំជាដើម។ ភារកិច្ចជាក់លាក់ជាក់លាក់របស់អ្នកពាក់ព័ន្ធ ក្នុងការរៀបចំកិច្ចប្រជុំនេះ មានរៀបរាប់ដូចខាងក្រោម :

| **អ្នកទទួលខុសត្រូវ** | **ភារកិច្ច** |
|---|---|
| អភិបាលស្រុក ខណ្ឌ | • ដឹកនាំរួមការរៀបចំ និងសម្របសម្រួលកិច្ចប្រជុំ |
| មន្ត្រីជំនាញស្រុក ខណ្ឌ (ចាត់តាំងដោយអភិបាលស្រុក ខណ្ឌ) | • រៀបចំការបង្ហាញ សម្ភារៈ និងឯកសារដែលពាក់ព័ន្ធនឹងកិច្ចប្រជុំ<br>• បង្ហាញពីសេចក្តីណែនាំ និងដំណើរការជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់ |
| មន្ត្រីការិយាល័យចំណុះ និងការិយាល័យជំនាញជុំវិញស្រុក ខណ្ឌ | • ចូលរួមពិភាក្សា និងកំណត់គម្រោងអន្តរឃុំ សង្កាត់ |
| តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ | • ចូលរួមពិភាក្សា និងកំណត់គម្រោងអន្តរឃុំ សង្កាត់ |
| មន្ត្រីសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងស្រុក ខណ្ឌ | • ជួយគាំទ្រមន្ត្រីជំនាញថ្នាក់ស្រុក ខណ្ឌក្នុងការបង្ហាញពីសេចក្តីណែនាំ<br>• ជួយមន្ត្រីថ្នាក់ស្រុក ខណ្ឌក្នុងការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ |
| មន្ត្រីគាំទ្របច្ចេកទេស | • ជួយមន្ត្រីថ្នាក់ស្រុក ខណ្ឌពន្យល់ពីលក្ខណៈបច្ចេកទេសនៃគម្រោងដែលជ្រើសរើស |

សកម្មភាពនៃកិច្ចប្រជុំនេះរួមមាន :

(១). កំណត់គម្រោងអន្តរឃុំ សង្កាត់ តាមរយៈការវិភាគ ដោយផ្អែកលើ :

- ទិន្នន័យស្តីពីស្ថានភាពស្រុក ខណ្ឌ

- ឯកសារពាក់ពន្ធផ្សេង១ដូចជា តារាងម៉ាទ្រិចនៃសកម្មភាពជាអាទិភាពរបស់ស្រុក ខណ្ឌឆ្នាំកន្លងមក ដោយជ្រើសរើសយកតែគម្រោង ដែលមិនទាន់មានការគាំទ្រ
- ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ និងផែនទីសកម្មភាពនៃការគ្រប់គ្រងធនធានធម្មជាតិ (បើមានជាពិសេសនៅក្នុងខេត្ត ក្រុង ដែលគាំទ្រដោយគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ) និងផែនទីផ្សេងទៀត
- ឧបករណ៍វិភាគ និងឯកសារពាក់ព័ន្ធផ្សេងទៀត
- ផែនទីស្រុក ខណ្ឌ
- បទពិសោធន៍ ។

(២). ស្រង់គម្រោងអន្តរឃុំ សង្កាត់ ដែលបានកំណត់ចូលក្នុងទម្រង់ទី ១.១ខ និងបំពេញព័ត៌មានផ្សេងទៀតនៅក្នុងទម្រង់នេះដូចជា ប្រភេទគម្រោង ទីតាំង និងឃុំ សង្កាត់ពាក់ព័ន្ធជាដើម ។

(៣). ស្រុក ខណ្ឌធ្វើការបូកសរុបគម្រោងអន្តរឃុំ សង្កាត់ ដែលបានកំណត់ (ទម្រង់ទី ១.១ខ) ជាមួយគម្រោងអន្តរឃុំ សង្កាត់ ដែលផ្ញើមកពីឃុំ សង្កាត់ (ទម្រង់ទី ១.១ក) ដោយប្រើទម្រង់ទី ១.២ ។

(៤). ត្រៀមសំរាប់ការរៀបចំកិច្ចប្រជុំបូកសរុបគម្រោងអន្តរឃុំ សង្កាត់រួមនៅថ្នាក់ស្រុក ខណ្ឌ ផ្អែកលើគម្រោងអន្តរឃុំ សង្កាត់ ដែលបានកំណត់ដោយឃុំ សង្កាត់ និងស្រុក ខណ្ឌ ។

**តារាងសង្ខេបសកម្មភាពប្រជុំកំណត់គម្រោងនៅថ្នាក់ស្រុក ខណ្ឌ**

| សកម្មភាព | លទ្ធផល | សម្ភារចាំបាច់ | រយៈពេល | អ្នកចូលរួម | អ្នកសំរបសំរួល | អ្នកសង្កេតការណ៍ |
|---|---|---|---|---|---|---|
| ១). កំណត់តំរូវការគម្រោងអន្តរឃុំ សង្កាត់ តាមរយៈវិភាគផែនទី ទិន្នន័យស្តីពីស្ថានភាពស្រុក ខណ្ឌ តារាងម៉ាទ្រិច និងបទពិសោធន៍<br>២). ស្រង់គម្រោងអន្តរឃុំ សង្កាត់ ចូលក្នុងទម្រង់ទី១.១ខ<br>៣). ស្រុក ខណ្ឌធ្វើការបូកសរុប គម្រោងអន្តរឃុំ សង្កាត់ ដែលបាន កំណត់ជាមួយគម្រោងអន្តរឃុំ សង្កាត់ ដែលផ្ញើមកពីឃុំ សង្កាត់ ដោយប្រើទម្រង់ទី១.២ និងត្រៀមសំរាប់ការរៀបចំ ប្រជុំបូកសរុបរួមនៅថ្នាក់ស្រុក ខណ្ឌ ។ | • បញ្ជីគម្រោងអន្តរឃុំ សង្កាត់កំណត់ដោយថ្នាក់ ស្រុក ខណ្ឌ | • ទម្រង់ទី១.១ខ<br>• ទម្រង់ទី១.២<br>• តារាងម៉ាទ្រិចនៃ សកម្មភាពជា អាទិភាពរបស់ស្រុក ខណ្ឌពីឆ្នាំកន្លងមក<br>• ផែនទីស្រុក ខណ្ឌ<br>• ផែនទីបញ្ហា មូលហេតុ ដំណោះ ស្រាយ និងផែនទី សកម្មភាព<br>• ទិន្នន័យស្តីពីស្ថាន ភាពស្រុក ខណ្ឌ | **១ថ្ងៃ** | • អភិបាល និង អភិបាលរងស្រុកខណ្ឌ<br>• ការិយាល័យជំនាញ ជុំវិញស្រុក ខណ្ឌ<br>• មន្ត្រីសម្របសម្រួល ស្រុក ខណ្ឌ<br>• តំណាងសមាគមក្រុម ប្រឹក្សាឃុំ សង្កាត់ | • អភិបាលស្រុក ខណ្ឌ និងមន្ត្រី ជំនាញថ្នាក់ ស្រុក ខណ្ឌ | • អង្គភាពរដ្ឋបាល មូលដ្ឋានខេត្ត ក្រុង<br>• មន្ទីរផែនការ<br>• . . . ។ល។ |

## ៤.២. ការបូកសរុប និងចាត់អាទិភាពគម្រោង

ការងារនេះរៀបចំនៅថ្នាក់ស្រុក ខណ្ឌ ក្នុងគោលបំណងបូកសរុបគម្រោងអន្តរឃុំ សង្កាត់ ដែលបានកំណត់ដោយឃុំ សង្កាត់ និងស្រុក ខណ្ឌ (ចំណុច ៤.១ សកម្មភាព "ក" និង "ខ") ។ សមាសភាពចូលរួមអង្គប្រជុំនេះរួមមាន អភិបាល និងអភិបាលរងស្រុក ខណ្ឌ ប្រធាន ឬអនុប្រធានមន្ទីរស្រុក ខណ្ឌ ការិយាល័យចំណុះសាលាស្រុក ខណ្ឌ និងការិយាល័យជំនាញជុំវិញ ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ជំទប់ទី១ និងទី២ ចៅសង្កាត់រងទី១ និងទី២ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជំនួយការគម្រោងឃុំ សង្កាត់ (បើមាន) តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រី សម្របសម្រួលស្រុក ខណ្ឌ ។

អភិបាលស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំ និងដឹកនាំរួមកិច្ចប្រជុំនេះ ដោយមានការសហការ និងគាំទ្រពីមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ។ ក្នុងកិច្ចដំណើរការអង្គប្រជុំ អភិបាលស្រុក ខណ្ឌត្រូវចាត់អភិបាលរង ឬមន្ត្រីជំនាញថ្នាក់ស្រុក ខណ្ឌណាម្នាក់ ដើម្បីធ្វើការសម្របសម្រួលកិច្ចប្រជុំ ចំណែកឯមន្ត្រីសម្របសម្រួលថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីគាំទ្របច្ចេកទេស ដែលប្រចាំការនៅក្នុងស្រុក ខណ្ឌនោះជាអ្នកសហការ និងគាំទ្រដូចជាការជួយពន្យល់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើស វិធីសាស្ត្រចាត់អាទិភាពគម្រោង និងសម្របសម្រួលលើការរៀបចំឯកសារ និងសម្ភារៈ ដែលជាតម្រូវការចាំបាច់សម្រាប់កិច្ចប្រជុំជាដើម ។ ភារកិច្ចជាក់លាក់ជាក់លាក់របស់អ្នកពាក់ព័ន្ធ ក្នុងការរៀបចំកិច្ចប្រជុំនេះ មានរៀបរាប់ដូចខាងក្រោម :

| **អ្នកទទួលខុសត្រូវ** | **ភារកិច្ច** |
|---|---|
| អភិបាលស្រុក ខណ្ឌ | • ចាត់ចែង រៀបចំ និងសម្របសម្រួលកិច្ចប្រជុំ |
| មន្ត្រីជំនាញស្រុក ខណ្ឌ (ចាត់តាំងដោយអភិបាលស្រុក ខណ្ឌ) | • រៀបចំការបង្ហាញគម្រោងអន្តរឃុំ សង្កាត់បូកសរុបពីថ្នាក់ឃុំ សង្កាត់ និងស្រុក ខណ្ឌ<br>• សម្របសម្រួលដំណើរការកិច្ចប្រជុំបូកសរុប និងចាត់អាទិភាពគម្រោងអន្តរឃុំ សង្កាត់ |
| មន្ត្រីចំណុះសាលាស្រុក ខណ្ឌ និងមន្ត្រីការិយាល័យជំនាញជុំវិញស្រុក ខណ្ឌ | • ចូលរួមពិភាក្សាក្នុងការបូកសរុប និងចាត់អាទិភាពគម្រោង អន្តរឃុំ សង្កាត់ |
| តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ | • ចូលរួមពិភាក្សាក្នុងការបូកសរុបគម្រោងអន្តរឃុំ សង្កាត់ តែពុំមានសិទ្ធិក្នុងការដាក់ពិន្ទុចាត់អាទិភាព ដើម្បីជ្រើសរើសគម្រោងឡើយ |
| មន្ត្រីសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងស្រុក ខណ្ឌ | • ជួយគាំទ្រមន្ត្រីជំនាញថ្នាក់ស្រុក ខណ្ឌក្នុងពេលបូកសរុប និងចាត់អាទិភាពគម្រោងអន្តរឃុំ សង្កាត់ |
| មន្ត្រីគាំទ្របច្ចេកទេស | • ជួយមន្ត្រីថ្នាក់ស្រុក ខណ្ឌពន្យល់ពីលក្ខណៈបច្ចេកទេសនៃគម្រោង |

| | |
|---|---|
| | ដែលបានកំណត់ និងចាត់អាទិភាព |
| មន្ត្រីថ្នាក់ឃុំ សង្កាត់ | • ចូលរួមពិភាក្សាបូកសរុប និងចាត់អាទិភាពគម្រោងអន្តរឃុំ សង្កាត់ |

សកម្មភាពនៃកិច្ចប្រជុំនេះ រួមមាន :

(១). តំណាងមន្ត្រីជំនាញថ្នាក់ស្រុក ខណ្ឌ (ចាត់តាំងដោយអភិបាលស្រុក ខណ្ឌ) បង្ហាញគម្រោងអន្តរឃុំ សង្កាត់ដែលបានបូកសរុប (ទម្រង់ទី១.២) ដល់សមាជិកអង្គប្រជុំ

(២). ពិនិត្យ ពិភាក្សា និងផ្ទៀងផ្ទាត់លើបញ្ជីគម្រោងអន្តរឃុំ សង្កាត់រួម (ទម្រង់ទី ១.២) ដោយប្រើប្រាស់ ផែនទីស្រុក ខណ្ឌ ផែនទីគ្រប់គ្រងធនធានធម្មជាតិ ទិន្នន័យស្ដីពីស្ថានភាពស្រុក ខណ្ឌ និងតារាង ម៉ាទ្រិច...ជាជំនួយ

(៣). កែសម្រួល និងឯកភាពលើបញ្ជីគម្រោងអន្តរឃុំ សង្កាត់ទម្រង់ទី១.២

(៤). ជ្រើសរើសគម្រោងអាទិភាពជំហានដំបូង ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យទាំង៥ (ទម្រង់ទី១.៣) :

១. គម្រោងដែលបម្រើផលប្រយោជន៍ឱ្យប្រជាពលរដ្ឋភាគច្រើន (**ផលប្រយោជន៍ច្រើនឃុំ សង្កាត់**)

២. គម្រោងដែលមានរួមចំណែកផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ

៣. គម្រោងដែលពុំមានផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន និងធនធានធម្មជាតិ

៤. គម្រោងដែលផ្ដល់ផលប្រយោជន៍ច្រើនដល់ស្ត្រី និងកុមារ

៥. គម្រោងដែលមាននិរន្តរភាព និងភាពជាម្ចាស់

(៥). ជ្រើសរើសយកគម្រោង ដែលឆ្លើយតបភាគច្រើននឹងលក្ខណៈវិនិច្ឆ័យទាំង៥ រួចបែងចែកគម្រោងទាំងនេះជាគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត ដោយប្រើប្រាស់ទម្រង់ទី២.១ និងទី២.២ ។ ក្នុងករណីគម្រោង ដែលបានឆ្លើយតបភាគច្រើនទៅនឹងលក្ខណៈវិនិច្ឆ័យទាំង៥ (ឆ្លើយតបចាប់ពី៣ លក្ខណៈវិនិច្ឆ័យឡើងទៅ) មានចំនួនច្រើនលើសលប់ គួរយកតែគម្រោងដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យទាំង៥ មកចាត់អាទិភាពបានហើយ តែបើចំនួននេះមិនច្រើនពេកទេ គួរយកគម្រោង ដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យចំនួន៤ និង៥មកចាត់អាទិភាព ។ បើគម្រោងដែលឆ្លើយតបភាគច្រើននឹងលក្ខណៈវិនិច្ឆ័យទាំង៥មានចំនួនតិច (ឧទាហរណ៍ចំនួនតិចជាង ២០ គម្រោង) គួរយកទាំងអស់មកចាត់អាទិភាពនៅសកម្មភាពបន្ទាប់ ។

(៦). ធ្វើការចាត់អាទិភាពគម្រោងដោយឃុំ សង្កាត់ :

ការចាត់អាទិភាពត្រូវធ្វើឡើងដាច់ពីគ្នា រវាងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត ។ មន្ត្រីថ្នាក់ស្រុក ខណ្ឌ (អភិបាល អភិបាលរង មន្ត្រីចំណុះសាលាស្រុក ខណ្ឌ និងមន្ត្រីការិយាល័យជំនាញជុំវិញស្រុក ខណ្ឌ) និងមន្ត្រីថ្នាក់ឃុំ សង្កាត់នីមួយៗ (មេឃុំ ចៅសង្កាត់ ជំទប់ទី១ និងទី២ ចៅសង្កាត់រងទី១ និងទី២ អ្នកទទួល បន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជំនួយការ

គម្រោងឃុំ សង្កាត់ បើមាន) ជាអ្នកដែលមានសិទ្ធិក្នុងការចាត់អាទិភាពនេះ ។ មន្ត្រីថ្នាក់ស្រុក ខណ្ឌ ទាំងអស់រួមទាំងចាត់ទុកជាអង្គភាពរួមមួយ និងមន្ត្រីមកពីឃុំ សង្កាត់នីមួយៗចាត់ទុកជា អង្គភាពមួយ ហើយដែលអង្គភាពនីមួយៗនេះមានតែមួយសំលេងប៉ុណ្ណោះ ក្នុងការចាត់អាទិភាពជ្រើសរើសគម្រោង ។ ការចាត់អាទិភាពនេះ អាចធ្វើឡើងតាមវិធីសាស្ត្រដូចខាងក្រោម មួយណាក៏បានអាស្រ័យទៅលើការជ្រើសរើសរបស់អង្គប្រជុំ ។

**វិធីសាស្ត្រទី១ :**

វិធីសាស្ត្រនេះជា វិធីសាស្ត្រចាត់អាទិភាពគម្រោងតាមរយៈការដាក់ពិន្ទុ ដោយរៀបគម្រោងតាមលំដាប់លេខរៀងពីតូចមកធំ ដើម្បីដាក់ពិន្ទុចាត់អាទិភាព ។ ការចាត់អាទិភាពនេះ ធ្វើឡើងដោយផ្អែកលើកម្រិតនៃសារៈសំខាន់របស់គម្រោងនីមួយៗ ហើយគម្រោងដែលមានពិន្ទុខ្ពស់ជាគេ ជាគម្រោងដែលមានសារៈសំខាន់ និងចាំបាច់ជាងគេ ។ លេខសម្រាប់ដាក់ពិន្ទុស្មើនឹងលេខរបស់គម្រោង ហើយពិន្ទុដែលខ្ពស់ជាងគេស្មើនឹងចំនួនសរុបនៃគម្រោង ។ ក្នុងការដាក់ពិន្ទុចាត់អាទិភាពគម្រោងនេះ ឃុំ សង្កាត់នីមួយៗមានក្រដាសដាក់ពិន្ទុពីរសន្លឹក (សំរាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តមួយសន្លឹក និងគម្រោងហេដ្ឋារចនសម្ព័ន្ធអរូបវន្តមួយសន្លឹក) និងស្រុក ខណ្ឌ (ស្រុក ខណ្ឌមានពីរសន្លឹកដែរ : មួយសន្លឹកសំរាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមួយសន្លឹកសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត) ដោយប្រើប្រាស់ទម្រង់ទី៣.១ និងទី៣.២។ ការដាក់ពិន្ទុត្រូវធ្វើ ដោយសម្ងាត់ទៅតាមក្រុមនៃឃុំ សង្កាត់នីមួយៗ និងស្រុក ខណ្ឌ។ បន្ទាប់មកធ្វើការបូកសរុបពិន្ទុនៃការចាត់អាទិភាពប្រើប្រាស់ទម្រង់ទី៤.១ និងទី៤.២ ។ ដើម្បីធានាការដាក់ពិន្ទុមិនឱ្យជាន់លេខគ្នា ក្នុងការបូកពិន្ទុ អ្នកសម្របសម្រួល ត្រូវធ្វើការណែនាំឱ្យបានច្បាស់ដល់អង្គប្រជុំ និងពិនិត្យឱ្យបានហ្មត់ចត់មុនពេលបូកសរុបពិន្ទុ ។

**វិធីសាស្ត្រទី២ :**

វិធីសាស្ត្រទី ២នេះជា វិធីសាស្ត្រចាត់អាទិភាពគម្រោង តាមរយៈការគូសរង្វង់លើលេខរៀងគម្រោងដែលឃុំ សង្កាត់ និងស្រុក ខណ្ឌមានការពេញចិត្ត និងយល់ថាមានសារៈសំខាន់ជាងគេ ។ គម្រោងដែលត្រូវចាត់អាទិភាព ត្រូវវាយក្នុងបញ្ជីដោយប្រើប្រាស់ទម្រង់ទី ៣.៣ និង ៣.៤ ដោយដាក់លេខរៀងតាមលំដាប់ពីតូចមកធំ ហើយដាក់បង្ហាញដល់អង្គប្រជុំទាំងមូល (បញ្ជីមួយសំរាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមួយទៀតសំរាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត)។ ឃុំ សង្កាត់នីមួយៗ និងស្រុក ខណ្ឌមានក្រដាសសពីរសន្លឹក (មួយសន្លឹកសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមួយសន្លឹកទៀតសំរាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត) ។ ដើម្បីចាត់អាទិភាពគម្រោងឃុំ សង្កាត់នីមួយៗ និងស្រុក

ខណ្ឌត្រូវធ្វើការពិភាក្សាក្នុងក្រុមសាមីរៀងៗខ្លួន ហើយជ្រើសរើសយកគម្រោង ដែលក្រុមគិតថា ជាគម្រោងមានសារៈសំខាន់ និងចាំបាច់ជាងគេ ។ ការកំណត់ចំនួនគម្រោង ដែលមានសារៈសំខាន់ និងចាំបាច់អាស្រ័យលើការឯកភាពរបស់អង្គប្រជុំ (ឧទាហរណ៍យកចំនួន ១/៣ នៃចំនួនគម្រោងសរុបដោយយកលេខគត់ចែកដាច់) នៃចំនួនគម្រោងសរុបចេញពីបញ្ជីគម្រោងនីមួយៗ ដែលដាក់បង្ហាញដោយកត់លេខរៀង ហើយគូសរង្វង់ពីខាងក្រៅ ។ បន្ទាប់មកក្រុមនីមួយៗផ្តល់គម្រោង ដែលខ្លួនបានជ្រើសរើសទៅអ្នកសម្របសម្រួល អង្គប្រជុំ ដើម្បីបូកសរុបសំលេង និងចាត់អាទិភាពដោយប្រើប្រាស់ទម្រង់ទី ៤.៣ និងទម្រង់ ទី៤.៤ ។ គម្រោង ដែលមានសំលេងច្រើនជាងគេគឺជា គម្រោងដែលមានអាទិភាពខ្ពស់ជាងគេ ។ ក្នុងករណី គម្រោងពីរ ឬច្រើនដែលមានសំលេងស្មើគ្នា អង្គប្រជុំអាចធ្វើការចាត់អាទិភាពគម្រោងទាំងនេះជាថ្មីម្តងទៀតតាមវិធីសាស្រ្តដដែល ។

(៧). ផ្ញើបញ្ជីគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត ដែលបានចាត់អាទិភាព មក គ.ប្រខេត្ត ក្រុង និងមន្ទីរផែនការខេត្ត ក្រុង ដើម្បីបញ្ចូលក្នុងបញ្ជីគម្រោងអាទិភាពរបស់ឃុំ សង្កាត់ សម្រាប់បែងចែកដល់មន្ទីរជំនាញ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការរៀបចំផែនការ និងដើម្បីឆ្លើយតបក្នុងសិក្ខាសាលាសមាហរណកម្មផែនការ ដោយប្រើទម្រង់ទី ៥.១ និង៥.២ ។

(៨). រៀបចំ និងបង្ហាញគម្រោងក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ។ អភិបាលស្រុក ខណ្ឌត្រូវចាត់តាំងមន្ត្រីជំនាញម្នាក់ ដើម្បីបង្ហាញគម្រោងនេះ ។

## តារាងសង្ខេបសកម្មភាពប្រជុំបូកសរុប និងចាត់អាទិភាពគម្រោងនៅថ្នាក់ស្រុក ខណ្ឌ

| សកម្មភាព | លទ្ធផល | សម្ភារចាំបាច់ | រយៈពេល | អ្នកចូលរួម | អ្នកសំរបសំរួល | អ្នកសង្កេតការណ៍ |
|---|---|---|---|---|---|---|
